ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តៈសៀមរាប
ក្រុងៈសៀមរាប
រដ្ឋបាលសង្កាត់ៈក្របីរៀល
លេខ.០១...../២២ ដ.ក

ដីកា
ស្តីពី
ការលើកទឹកចិត្តយុវជនចូលរួមក្នុងកិច្ចការសង្គម

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់។
- បានឃើញអនុក្រឹត្យលេខ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ចទៅអោយក្រុមប្រឹក្សាឃុំ/សង្កាត់។
- បានឃើញប្រកាសលេខ៣៦០៥ ប្រ ក ចុះថ្ងៃទី២៧ ខែ មិថុនាឆ្នាំ២០២២ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាសង្កាត់ ប្រធានក្រុមប្រឹក្សាសង្កាត់ ចៅសង្កាត់ ចៅសង្កាត់រងទី១ ចៅសង្កាត់រងទី២ និងសមាជិកក្រុមប្រឹក្សាសង្កាត់នៃសង្កាត់ក្របីរៀល។
- យោងតាមតម្រូវការចាំបាច់របស់រដ្ឋបាលសង្កាត់ក្របីរៀល ដោយយល់ឃើញថា បញ្ហាកង្វះការចូលរួមរបស់យុវជនក្នុងកិច្ចការសង្គម ជាពិសេសការចូលរួមនៅក្នុងការធ្វើផែនការអភិវឌ្ឍន៍សង្កាត់អាចមិនឆ្លើយតបទៅនឹងតម្រូវការរបស់យុវជននៅក្នុងសហគមន៍នៃសង្កាត់។
- យោងតាមការពិភាក្សាសម្រេចលើសេចក្តីព្រាងដីកា ស្តីពី ការលើកទឹកចិត្តដល់យុវជនក្នុងការចូលរួមក្នុងកិច្ចការសង្គមនៅក្នុងសង្កាត់ក្របីរៀល កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២ និងដោយមើលឃើញពីការប្រឈមរបស់យុវជនដែលពុំសូវមានឱកាសក្នុងការចូលរួមក្នុងកិច្ចការសង្គម ដើម្បីលើកទឹកចិត្តដល់យុវជនឱ្យចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាសង្កាត់។
- យោងកិច្ចប្រជុំសាមញ្ញលើកទី២អាណត្តិទី ៥ របស់ក្រុមប្រឹក្សាសង្កាត់ក្របីរៀល នាថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០២២

ក្រុមប្រឹក្សាសង្កាត់ក្របីរៀល

សម្រេច

ប្រការ១._ដីកានេះមានគោលបំណង លើកកម្ពស់សិទ្ធិ និងការចូលរួមរបស់យុវជនក្នុងកិច្ចការសង្គម និងផ្តល់ឱកាសដល់យុវជនទាំងពីរភេទបានចូលរួមយ៉ាងសកម្មនៅក្នុងការផ្តល់យោបល់និងលើកឡើងនូវកង្វល់នានាដែលពាក់ព័ន្ធទៅនឹងតម្រូវការរបស់យុវជនតាមគោលគំនិត និងក្តីស្រមៃរបស់ខ្លួន។

ប្រការ២._ដីកានេះមានវិសាលភាពអនុវត្តតែនៅក្នុងដែនដី នៃសង្កាត់ក្របីរៀល។

ប្រការ៣._រដ្ឋបាលសង្កាត់ផ្តល់ឱកាសលើកទឹកចិត្តឱ្យក្រុមយុវជន និងតំណាងប្រជាពលរដ្ឋចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់

Scanned with CamScanner

ក្រុមប្រឹក្សាសង្កាត់។

ប្រការ៤. រដ្ឋបាលសង្កាត់ផ្តល់ឱកាស និងលើកទឹកចិត្តឱ្យក្រុមយុវជនចូលរួមនៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ ៥ ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់សង្កាត់។

ប្រការ៥. រដ្ឋបាលសង្កាត់ នឹងស្វែងរកកិច្ចសហការទូលំទូលាយ ជាមួយអ្នកពាក់ព័ន្ធ រួមទាំងអង្គការនានា ជាពិសេសយុវជនដែលទទួលបានជោគជ័យក្នុងការចូលរួមក្នុងកិច្ចការសង្គមដើម្បីចែករំលែកបទពិសោធន៍ និងផ្តល់ការបណ្តុះបណ្តាលដល់យុវជនពីសិទ្ធិមនុស្ស ប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងសារៈសំខាន់នៃការចូលរួមរបស់យុវជននៅក្នុងការអភិវឌ្ឍមូលដ្ឋាន។

ប្រការ៦. រដ្ឋបាលសង្កាត់ នឹងរៀបចំឱ្យមានការដាក់បង្ហាញអំពីតារាងតម្លៃសេវារដ្ឋបាល នៅសាលាសង្កាត់ឱ្យបានទូលំទូលាយ ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងពីតម្លៃសេវារដ្ឋបាលរបស់សង្កាត់ និងបង្កើនការផ្សព្វផ្សាយពីនីតិវិធីនៃការផ្តល់សេវា ដើម្បីឱ្យមានតម្លាភាព។

ប្រការ៧. រដ្ឋបាលសង្កាត់ នឹងចែករំលែកព័ត៌មានពាក់ព័ន្ធពីកិច្ចការសង្គម និងផ្តល់ឱកាសសម្រាប់ការចូលរួមរបស់យុវជនជាមួយក្រុមប្រឹក្សាសង្កាត់ដល់ប្រជាពលរដ្ឋក្នុងសង្កាត់ ជាពិសេសយុវជន តាមរយៈការបិទផ្សាយលើក្តារព័ត៌មាននៅសាលាសង្កាត់ និងទំព័រហ្វេសបុកផ្លូវការរបស់រដ្ឋបាលសង្កាត់។

ប្រការ៨. រដ្ឋបាលសង្កាត់ នឹងបង្កលក្ខណៈងាយស្រួលដល់បណ្តាញ/ក្រុមយុវជនបានជួបជុំពិភាក្សាគ្នា និងផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស ប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងតួនាទីរបស់យុវជនក្នុងការចូលរួមក្នុងកិច្ចការសង្គមដល់ប្រជាពលរដ្ឋ ជាពិសេសយុវជននៅក្នុងសហគមន៍ឱ្យបានយល់ដឹងយ៉ាងទូលំទូលាយ។

ប្រការ៩. រដ្ឋបាលសង្កាត់ ជួយសម្រួលរាល់ឯកសារដែលទាក់ទងទៅនឹងតម្រូវការរបស់យុវជនជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធផ្សេងៗទៀត។

ប្រការ១០. ជីកានេះអាចធ្វើការកែសម្រួលបាន តាមតម្រូវការចាំបាច់ ស្របតាមការវិវត្តរបស់រដ្ឋបាលសង្កាត់។

ប្រការ១១. ជីកានេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible]ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ២០២២

ប្រធានក្រុមប្រឹក្សាសង្កាត់

ឈួន យ៉ែប

ចម្លងជូន

- រដ្ឋបាលក្រុងសៀមរាប
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមក្រុងសៀមរាប
  "ដើម្បីគោរពជូនជ្រាប"
- មេភូមិគ្រប់ភូមិ

  "ដើម្បីសហការអនុវត្តន៍"

- ឯកសារ-កាលប្បវត្តិ

Scanned with CamScanner